**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
**អគ្គលេខាធិការដ្ឋាន**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧
## ថ្ងៃអង្គារ ទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយស សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា នៅព្រឹកថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥ វេលាម៉ោង ០៨:០០នាទី រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ដោយមានវត្តមានសមាជិក-សមាជិការដ្ឋសភា ពេលផ្តើមសម័យប្រជុំចំនួន **១១០រូប**។

អង្គសភាបានអនុម័តយល់ព្រមលើរបៀបវារៈបន្តសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ ចំនួន៤ ដោយមានសំឡេង ១១៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូល ដែលមានដូចតទៅ៖

**១**-ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

**២**-សេចក្តីព្រាងច្បាប់ស្តីពី ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក។

**ចំពោះលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ មានដូចខាងក្រោម៖**

**១**-ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

សេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បានរៀបចំឡើង ក្នុងគោលបំណងកំណត់អំពីការផ្តន្ទាទោសចំពោះបុគ្គលទាំងឡាយដែលមិនទទួលស្គាល់ ឬសម្រាល ឬបដិសេធ ឬជំទាស់អត្ថិភាពនៃឧក្រិដ្ឋកម្ម ឬលើកតម្កើងឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងដែលអត្ថិភាពនៃឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានទទួលស្គាល់ដោយសេចក្តីសម្រេចស្ថាពរ ឬនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជា ប្រជាធិបតេយ្យ ដែលសរសេរកាត់ថា "អ.វ.ត.ក." ក្នុងគោលបំណងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងទប់ស្កាត់កុំឱ្យឧក្រិដ្ឋកម្មទាំងនេះវិលត្រឡប់មកវិញនៅកម្ពុជា។

-សេចក្តីព្រាងច្បាប់នេះមាន៧មាត្រា។

-**ឯកឧត្តម អង្គ វង្ស វឌ្ឍានា** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា ពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់។

-**ឯកឧត្តម កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសហការីជាអ្នកការពារសេចក្តីព្រាងច្បាប់។

-សមាជិករដ្ឋសភាដែលឡើងមានមតិ ក្នុងការពិភាក្សាសេចក្តីព្រាងច្បាប់នេះ មានចំនួន ២រូបគឺ **ឯកឧត្តម ឈាង វុន** តំណាងរាស្ត្រមណ្ឌលខេត្តបាត់ដំបង និង **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន** តំណាងរាស្ត្រមណ្ឌលខេត្តតាកែវ។



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិច:sg@na.gov.kh គេហទំព័រ: www.na.gov.kh

-អង្គសភាបានអនុម័តលើសេចក្តីព្រាងច្បាប់ទាំងមូល មានចំនួន **១១៥សំឡេង** នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**២**-ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក។

សេចក្តីព្រាងច្បាប់ស្តីពី ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក បានរៀបចំឡើង ក្នុងគោលបំណង កំណត់អំពីលក្ខខណ្ឌ សមត្ថកិច្ច និងនីតិវិធីក្នុងការចាត់ចែងជាបណ្តោះ អាសន្ននូវវត្ថុចាប់យក នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ក្នុងគោលបំណងរក្សាតម្លៃសេដ្ឋកិច្ចនៃវត្ថុចាប់យកទាំងនោះ ព្រមទាំងការពារផលប្រយោជន៍របស់ម្ចាស់នៃវត្ថុចាប់យក ឬ របស់បុគ្គលពាក់ព័ន្ធផ្សេងទៀត និងការពារផលប្រយោជន៍សាធារណៈ។

ម្យ៉ាងទៀត សេចក្តីព្រាងច្បាប់នេះ ក៏មានគោលដៅ បំពេញបន្ថែមនូវភាពខ្វះចន្លោះនៃបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌផង និងអាចឱ្យព្រះរាជអាជ្ញា និងចៅក្រមធ្វើការចាត់ចែងនូវវត្ថុចាប់យកនៅក្នុងគ្រប់ដំណាក់កាលនីតិវិធីព្រហ្មទណ្ឌផង សំដៅធានារក្សាតម្លៃសេដ្ឋកិច្ចនៃវត្ថុចាប់យក ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់ នៃវត្ថុចាប់យកឬបុគ្គលពាក់ព័ន្ធផ្សេងទៀត និងផលប្រយោជន៍សាធារណៈ ព្រមទាំងធានាការកាត់បន្ថយបន្ទុកចំណាយក្នុងការគ្រប់គ្រងនិងថែរក្សានូវវត្ថុចាប់យក។

-សេចក្តីព្រាងច្បាប់នេះ មាន៤ជំពូក ចែកចេញជា១៥មាត្រា។

-**ឯកឧត្តម អង្គ វង្ស វឌ្ឍានា** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា ពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់។

-**ឯកឧត្តម កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសហការីជាអ្នកការពារសេចក្តីព្រាងច្បាប់។

-សមាជិករដ្ឋសភាដែលឡើងមានមតិ ក្នុងការពិភាក្សាសេចក្តីព្រាងច្បាប់នេះ មានចំនួន២រូប គឺ **ឯកឧត្តម ទី សុគន្ធ** តំណាងរាស្ត្រមណ្ឌលខេត្តកណ្តាល និង **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន** តំណាងរាស្ត្រមណ្ឌលខេត្តតាកែវ។

-អង្គសភាបានអនុម័តលើសេចក្តីព្រាងច្បាប់ទាំងមូល មានចំនួន ១១៥សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

អាស្រ័យដោយសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ បានចាប់ផ្តើមដំណើរការនៅថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ មកដល់ថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥ មានរយៈពេលលើស ៣ខែ ក្នុងរយៈពេលនេះ រដ្ឋសភា សម្រេចបានលទ្ធផលការងារដូចតទៅ ៖

**ក**-សម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ បានដំណើរការតាមរបៀបវារៈ ដូចតទៅ៖

១-ព្រះរាជសារព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជូនសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧។

២-របាយការណ៍សង្ខេបស្តីពី សកម្មភាពការងាររបស់រដ្ឋសភាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី២ និងលើកទី៣ នីតិកាលទី៧។

៣-សម្រេចអំពីសុពលភាពនៃអាណត្តិរបស់បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ចំនួន ២រូប គឺ៖

-**ឯកឧត្តម ហ៊ី វីរៈ** ជាតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ឆ្នាំង ជំនួស **សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល** ដែលបានទទួលមរណភាព។

-**លោកជំទាវ យស ឋានារី** ជាតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ ជំនួស **ឯកឧត្តម ជា ចាន់តូ** ដែលបានទទួលមរណភាព។

៤-អនុម័តសេចក្តីព្រាងច្បាប់ ចំនួន ៧។

៥-អនុម័តសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១។

៦-បោះឆ្នោតជ្រើសតាំង **ឯកឧត្តម អ៊ិត រ៉ាឌី** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់អាណត្តិទី៣ ជ្រើសតាំងដោយរដ្ឋសភា នីតិកាលទី៧។

៧-បោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការកែសម្រួល និងតែងតាំងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ២រូប៖

-ឯកឧត្តម ប្រាក់ សុខុន ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

-ឯកឧត្តម សុខ ចិន្តាសោភា ជាឧបនាយករដ្ឋមន្ត្រី ។

**ខ**-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រជុំ ចំនួន ៦លើក ។

**គ**-គណៈកម្មការនានានៃរដ្ឋសភា បានបំពេញការងារតាមតួនាទី និងភារកិច្ចដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងបទដ្ឋានគតិយុត្ត ដែលមានលទ្ធផលដូចតទៅ៖

១-គណៈកម្មការ បានប្រជុំផ្ទៃក្នុង ចំនួន ៣៤លើក។

២-គណៈកម្មការ បានប្រជុំពិនិត្យ និងសិក្សាសេចក្តីព្រាងច្បាប់ ចំនួន ៧ និង សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១ ។

៣-គណៈកម្មការ បានចុះបំពេញបេសកកម្មនៅតាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ចំនួន ៨លើក ដើម្បីស្វែងយល់អំពីការអនុវត្តច្បាប់ កម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ រួមមាន៖

-ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

-ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្ត រតនគិរី ខេត្តមណ្ឌលគិរី ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែប និងខេត្តតាកែវ ។

**ឃ**-ការងារការទូតសភា ថ្នាក់ដឹកនាំរដ្ឋសភា គណៈកម្មការនានានៃរដ្ឋសភា និងសមាជិក សមាជិការដ្ឋសភា បានបំពេញការងារយ៉ាងសកម្មទាំងក្នុងក្របខណ្ឌ ទ្វេភាគី និងក្របខណ្ឌពហុភាគី ដើម្បីពង្រឹង ពង្រីក និងលើកកម្ពស់វិស័យការទូតសភា ដែលជាកិច្ចការការបរទេសរបស់រដ្ឋសភា ក្នុងការចូលរួមចំណែកដល់ការពង្រឹងពង្រីក និងកិច្ចទំនាក់ទំនងចំណងមិត្តភាព និងសហប្រតិបត្តិការជាមួយសភា និងរដ្ឋាភិបាលនៃប្រទេសនានា ដៃគូអភិវឌ្ឍន៍ និងអង្គទូតរបស់ប្រទេសនានា ព្រមទាំងពង្រីក និងលើកកម្ពស់តួនាទីរដ្ឋសភាកម្ពុជា ក្នុងវេទិកាអន្តរសភានានា លើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម បរិស្ថាន ទេសចរណ៍ អប់រំ និងវប្បធម៌ ព្រមទាំងការលើកកម្ពស់សិទ្ធិស្ត្រី និងសមភាព យេនឌ័រ ដែលមាន៖

**១**-ក្របខណ្ឌទ្វេភាគី

ថ្នាក់ដឹកនាំរដ្ឋសភា គណៈកម្មការនានានៃរដ្ឋសភា និងសមាជិក សមាជិការដ្ឋ សភា បានជួបសវនាការ សម្តែងការគួរសម និងពិភាក្សាការងារជាមួយសភាប្រទេសនានា និងឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូតប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រឹងពង្រីក និងលើកកម្ពស់កិច្ចទំនាក់ទំនងចំណងមិត្តភាព និងសហប្រតិបត្តិការ ចំនួន ៤១លើក មានជាអាទិ៍៖

-សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា បាន៖

១-ជួបសវនាការ សម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ប្រចាំព្រះរាជាណាចក្រកម្ពុជា ភ្ញៀវជាតិនិងអន្តរជាតិ និងអង្គការនានា ចំនួន ១៩លើក ។

២-ជួបសវនាការ និងពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

៣-ជួបសវនាការ និងពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភានៃប្រទេសម៉ាឡេស៊ី។

-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា បាន៖

១-ជួបសវនាការ និងពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ ចំនួន ១លើក។

២-ទទួលគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភា នៃប្រទេសម៉ាឡេស៊ី ។

-ឯកឧត្តម **ខួង ស្រេង** អនុប្រធានទី២រដ្ឋសភា បានទទួលគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភានៃប្រទេសម៉ាឡេស៊ី។

**ខ**-ក្របខណ្ឌពហុភាគី

ថ្នាក់ដឹកនាំរដ្ឋសភា និងសមាជិក សមាជិការដ្ឋសភា បានចូលរួមសន្និសីទ សិក្ខាសាលា កិច្ចប្រជុំនានា នៃអន្តរសភា ចំនួន ១៧លើក មានជាអាទិ៍៖

-រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ធ្វើជាសហប្រធាន និងរៀបចំសម័យប្រជុំ ពេញអង្គលើកទី១១ នៃសភាអន្តរជាតិដើម្បីភាពអត់ឱន និងសន្តិភាព (IPTP)ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុម័តធម្មនុញ្ញសន្តិភាពសាកល។

-សមាជិក សមាជិការដ្ឋសភា បានចូលរួមសន្និសីទ សិក្ខាសាលា កិច្ចប្រជុំនានា នៃអន្តរសភានានា ដើម្បីចែករំលែកបទពិសោធ និងវិធីដោះស្រាយបញ្ហានានា របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ និងសកលលោក បញ្ហាសំខាន់ៗទាំងនោះរួមមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម កសិកម្ម បរិស្ថាន ទេសចរណ៍ អប់រំ សុខាភិបាល និងវប្បធម៌ ព្រមទាំងការលើកកម្ពស់សិទ្ធិស្ត្រី ការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រី និង សមភាពយេនឌ័រ ។

**ង**-ការងារទទួលពាក្យបណ្តឹង គណៈកម្មការនានានៃរដ្ឋសភា បានទទួលពាក្យ បណ្តឹងពីប្រជាពលរដ្ឋចំនួន ៤រឿង ដោយកំពុងពិនិត្យ និងសិក្សាចំនួន ១រឿង និង តម្កល់ទុកឥតបាត់ការចំនួន ៣រឿង ។

**ច**-ការងារចុះមូលដ្ឋានតាមមណ្ឌលរាជធានី ខេត្ត ថ្នាក់ដឹកនាំរដ្ឋសភា សមាជិក សមាជិការដ្ឋសភា បានបំពេញការងារតាមតួនាទី និងភារកិច្ចដូចមានកំណត់ក្នុង រដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ច្បាប់ និងបទដ្ឋានគតិយុត្តនានា ក្នុងការចុះសួរសុខទុក្ខ និងដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋនៅតាមមណ្ឌលរាជធានី ខេត្ត និងសកម្មភាពផ្សេងៗយ៉ាងសកម្ម ដូចមានចែងក្នុងរបាយការណ៍ស្តីពី សកម្មភាពការងាររបស់រដ្ឋសភា នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧។

**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា** បានប្រកាស បិទសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ ចាប់ពីថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥ នេះតទៅ។

សម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ បានប្រកាសបិទនៅវេលាម៉ោង១០:២០នាទី នាថ្ងៃខែឆ្នាំដដែល។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមសាធារណជនជ្រាបជាព័ត៌មាន៕

ថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥

អគ្គលេខាធិការដ្ឋានរដ្ឋសភា